**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**



**គណៈកម្មាធិការនាយក**

**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គឹម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សីន សែត**
**Mr. SEN Set**


ស.ប្រ.ក.៣/លេខ ២៥/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត កណ្តាល

*ភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨៥នាក់ មកពីស្រុកផ្សេងគ្នា និងក្រុង នៅក្នុងខេត្តកណ្តាល ដែលមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ២៥% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកណ្តាល កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។

អភិបាលរងក្រុងតាខ្មៅលោក **នូ សាខន** បានលើកឡើងថា សិក្ខាសាលានេះនឹងផ្តល់ឱកាសដល់ម្ចាស់ឆ្នោតធ្វើការបង្ហាញពីតម្រូវការរបស់ខ្លួនជូនមន្ត្រីជាប់ឆ្នោត ហើយក៏ជាការរួមចំណែករបស់សង្គមស៊ីវិលដើម្បីផ្សារភ្ជាប់តំរូវការរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលទៅអោយមន្ត្រីជាប់ឆ្នោតផងដែរ ។

អ្នកតំណាងរាស្ត្រឯកឧត្តម **ឃឹម ឡាគី** មណ្ឌលកណ្តាលមកពីគណបក្សសមរង្ស៊ី និងអ្នកតំណាងរាស្ត្រឯកឧត្តម **អ៊ូ ច័ន្ទរិទ្ធ** មកពីគណបក្សសិទ្ធិមនុស្ស និងសមាជិកក្រុមប្រឹក្សាខេត្តកណ្តាល លោកជំទាវ **នួន និរតី** មកពីគណបក្សប្រជាជនកម្ពុជាបានទទួលយកលទ្ធផល និងឯកភាពទាំងស្រុងទៅលើចំនុចទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោត ។

អ្នកតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាខេត្តកណ្តាលបានមានប្រសាសន៍ថា សិក្ខាសាលានេះពិតជាមានសារៈសំខាន់ណាស់ ហើយរាល់តំរូវការទាំងអស់របស់ប្រជាពលរដ្ឋ អ្នកជាប់ឆ្នោតនឹងខិតខំដោះស្រាយ និងមានជំនឿជឿជាក់ថា នឹងសំរេចបានជោគជ័យជាបន្តបន្ទាប់ ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តកណ្តាលដូចខាងក្រោម:

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើត ស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកណ្តាលរួមមាន:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០នៅក្នុងខេត្ត កណ្តាល** |
|---|
| ១) សុំឱ្យរដ្ឋាភិបាលផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសក្នុងការ ដាំដំណាំស្រូវ ពោត សណ្តែក បន្លែ... និងបច្ចេកទេសការចិញ្ចឹមសត្វជ្រូក គោ ក្របី មាន់ ទា ត្រី ដល់កសិករ គ្រប់ស្រុកទូទាំងខេត្តកណ្តាល ដោយមួយឆ្នាំមាន ២ វគ្គ ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលស្វែងរកទីផ្សារសំរាប់លក់ផលិតផល កសិកម្ម ( ស្រូវ ពោត សណ្តែក បន្លែ...) ហើយតម្លៃឱ្យ បានចំណេញ ៥០% នៃការចំណាយទៅលើការផលិត ចាប់ពីឆ្នាំ ២០១០ តទៅ។ និងបង្កើតឱ្យមានកន្លែងទិញ ស្រូវសម្រាប់ស្តុកទុកនៅទីរួមខេត្តកណ្តាលអោយបានក្នុងឆ្នាំ ២០១០។ |
| ៣) សូមកុំលក់ក្រដាសមេរៀនឱ្យសិស្សនៅក្នុងថ្នាក់រៀននៅ គ្រប់សាលាទាំងអស់ទូទាំងខេត្តកណ្តាលចាប់ពីដើមឆ្នាំ ២០១០តទៅ។ ត្រូវតំឡើងប្រាក់បៀវត្សមន្ត្រីរាជការទាំងអស់មានប្រាក់បៀវត្សរ៍យ៉ាងតិច ១៥០ ដុល្លារអាមេរិក ក្នុងមួយខែ នៅទូទាំងខេត្ត កណ្តាលទាំងអស់ដោយអនុវត្តចាប់ពីដើមឆ្នាំ ២០១០ តទៅ។ |
| ៤) សុំឱ្យរាជរដ្ឋាភិបាលបើកបឹង ព្រៃក ប្រឡាយនៅក្នុងខេត្ត កណ្តាលដែលក្រុមហ៊ុនឯកជនបានបិទ ដោយត្រូវបើក ចាប់ពីឆ្នាំ ២០១០ តទៅ ដើម្បីឱ្យប្រជាពលរដ្ឋបាន បង្កបង្កើនផល និងអាចនេសាទបាន។ |
| ៥) ពង្រឹងការអនុវត្តច្បាប់ដោយផ្តន្ទាទោសមន្ត្រីអនុវត្តច្បាប់ ដែលប្រព្រឹត្តខុសច្បាប់ដែលកំពុងតែមានស្រាប់ដោយផ្តន្ទាទោសឱ្យមានយ៉ាងហោចណាស់៧០% នៃករណីរំលោភច្បាប់ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៦) មិនអោយមានការយកលុយបន្ថែមទៅលើតំលៃពន្ធផ្លូវដែលមានដាក់នៅលើប័ណ្ណសំគាល់បង់ពន្ធយានជំនិះ នៅទូទាំងខេត្តកណ្តាល ដោយអនុវត្តអោយបាន ១០០% អោយបាននៅឆ្នាំ ២០១០ តទៅ។ |
| ៧) សុំបណ្តាញអគ្គិសនីតភ្ជាប់ចូលទៅក្នុងស្រុកកណ្តាលស្ទឹង ស្រុកខ្សាច់កណ្តាល ស្រុកមុខកំពូល ស្រុកល្វាឯម ស្រុកពញាឮ និងស្រុកលើកដែក ហើយតម្លៃអគ្គិសនីគឺ៤០០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ។ |
| ៨) សុំឱ្យរាជរដ្ឋាភិបាលផ្តល់ប្រាក់កម្ចីដោយមានការប្រាក់ទាប ត្រឹម ៣% ក្នុងមួយឆ្នាំ ទៅលើវិស័យកសិកម្ម ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៩) គ្រប់មន្ទីពេទ្យរដ្ឋទាំងអស់ក្នុងខេត្តកណ្តាលត្រូវអនុវត្តគោលនយោបាយមិនយកលុយចំពោះប្រជាពលរដ្ឋក្រីក្រដែលព្យាបាលនៅមន្ទីរពេទ្យអោយបាន ១០០%ចាប់ពី ដើមឆ្នាំ ២០១០ តទៅ។ |
| ១០) គ្រប់មណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋទាំងអស់ក្នុងខេត្តកណ្តាលត្រូវមានគ្រូពេទ្យប្រចាំការ២៤ម៉ោង ហើយគ្រប់គ្រូពេទ្យទាំងអស់ត្រូវគោរព ម៉ោងធ្វើការឱ្យបានទៀងទាត់ ចាប់ពីដើមឆ្នាំ ២០១០ តទៅ។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ, ការីតាស់ (CARITAS) ដែលក្នុងនោះ មានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកតាខ្មៅ ស្រុកស្អាង ស្រុកកណ្តាលស្ទឹង ស្រុកកៀនស្វាយ ស្រុកពញាឮ ស្រុកល្វាឯម ស្រុកខ្សាច់កណ្តាល ស្រុកមុខកំពូល និងក្រុងតាខ្មៅ នៅក្នុងខេត្តកណ្តាល។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ច័ន្ទ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦